# របាយការណ៍ស្តីពីការតាមដានជំងឺកូវីដ-19

ក្រសួងសុខាភិបាល

របាយការណ៍លេខ: 63

របាយការណ៍ថ្ងៃទី21 ខែឧសភា ឆ្នាំ2020

## ព័ត៌មានសំខាន់ៗ

- ពុំមានករណីជំងឺកូវីដ-19 ថ្មីទេចាប់តាំងពីថ្ងៃទី11 ខែមេសា2020មក។
- វិទ្យាស្ថានប៉ាស្ទ័រកម្ពុជាបានធ្វើតេស្តវត្ថុវិភាគចំនួន66កាលពីម្សិលមិញក្នុងនោះជាលើកទីមួយដែលមានវត្ថុវិភាគតាមដានចំនួន 54 មកពីខេត្តចំនួន8។
- នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល/វិទ្យាស្ថានប៉ាស្ទ័រកម្ពុជាកំពុងរៀបចំពិនិត្យមើលឡើងវិញនៃការរកឃើញ 123 ករណីដំបូងនៅក្នុងប្រទេសកម្ពុជាដើម្បីវាយតម្លៃពីគុណភាពនៃការងារការតាមដានកំឡុងពេលនៃការឆ្លើយតបទៅនឹងជំងឺកូវីដ-19វគ្គទីមួយ។ យើងកំពុងសម្ភាសន៍ក្រុមអ្នកស្វែងរកអ្នកប៉ះពាល់ធ្វើការនៅជួរមុខដើម្បីចង់ដឹងថាតើករណីឈឺជាបុគ្គលនិងជាក្រុមត្រូវបានរកឃើញតាមរបៀបណា តើកត្តាអ្វីដែលបង្កឱ្យបាត់ឱកាសនៃការរកឃើញករណីឈឺ និងតើគួរធ្វើដូចម្តេចដើម្បីធ្វើឱ្យប្រសើរដល់ការឆ្លើយតបទៅនឹងជំងឺកូវីដ-19នៅវគ្គទីពីរ។
- រដ្ឋាភិបាលកំពុងសាកល្បងការត្រួតពិនិត្យអ្នកធ្វើដំណើរតាមយន្តហោះក្នុងចំណោមជើងហោះហើរពីរដែលហោះពីទីក្រុងសេអ៊ូលប្រទេសកូរ៉េ។ អ្នកធ្វើដំណើរនឹងត្រូវនាំទៅដាក់នៅមូលដ្ឋានទ័ពអាកាសមួយកន្លែងក្បែរព្រលានយន្តហោះដើម្បីយកវត្ថុវិភាគនិងត្រូវសម្រាកនៅទីនោះមួយយប់រហូតទទួលបានលទ្ធផលនៃការធ្វើតេស្ត។ ប្រសិនបើមានអ្នកណាម្នាក់មានលទ្ធផលតេស្តវិជ្ជមានអ្នកធ្វើដំណើរទាំងនៅអស់នឹងត្រូវនាំទៅមណ្ឌលចត្តាឡីស័កមួយកន្លែងនៅភ្នំពេញដើម្បីដាក់ឱ្យនៅដាច់ដោយឡែករយៈពេល14ថ្ងៃ។

**ចំនួនករណីសរុប (ករណីថ្មី)**

| | |
|---|---|
| ករណីឈឺ | : 122 (0) |
| ករណីប្រហែលឆ្លង | : 1 |
| ករណីស្លាប់ | : 0 |

**អ្នកប៉ះពាល់បច្ចុប្បន្ន**

| | |
|---|---|
| សរុប | : 0 |
| អ្នកមានហានិភ័យខ្ពស់ | : 0 |

## ករណីឈឺបញ្ជាក់ដោយមន្ទីរពិសោធន៍

រហូតមកដល់ថ្ងៃទី21 ខែឧសភា ឆ្នាំ2020 មានអ្នកជំងឺកូវីដ-19 ចំនួន122នាក់ ករណីប្រហែលឆ្លង1ករណី ក្នុងនោះ85នាក់ជាករណីជំងឺនាំចូលពីបរទេស 38នាក់ជាករណីឆ្លងក្នុងប្រទេសកម្ពុជាឬនៅបរទេសតាមការប៉ះពាល់ជាមួយអ្នកជំងឺកូវីដ-19 ។

ករណីឆ្លងនៅក្រៅប្រទេស ត្រូវបានរាយការណ៍ថា អាចនឹងឆ្លងនៅក្នុងប្រទេសចំនួនប្រាំបី៖ ប្រទេសបារាំង (37) ម៉ាឡេស៊ី (34) ថៃ (5) វៀតណាម (3) ចិន (1) អូទ្រីស (1) អង់គ្លេស (1) ជប៉ុន (1) និង 2 នាក់ទៀតមានព័ត៌មានមិនច្បាស់ ។ អ្នកជំងឺទាំងនោះមានសញ្ជាតិចំនួន12 រួមមានជនជាតិខ្មែរ (51 នាក់) បារាំង

*សម្គាល់: របាយការណ៍នេះរៀបរៀងឡើងដោយនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាលសហការជាមួយមជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងអង្គការសុខភាពពិភពលោក*

(39នាក់) ម៉ាឡេស៊ី (13នាក់) អង់គ្លេស (5នាក់)  ចិន(3នាក់) វៀតណាម (3នាក់) អាមេរិក (2នាក់) ឥណ្ឌូណេស៊ី (2នាក់) កាណាដា (2នាក់)  បែលហ្ស៊ិក(1នាក់) ស៊ុយអែត (1នាក់) និងកុងហ្គូ (1នាក់) ។ ករណីឈឺទាំងនោះត្រូវបានរកឃើញនៅក្នុងខេត្តចំនួន13 (សូមមើលផែនទី)។

**ក្រាហ្វិកទី1**: ករណីឈឺបញ្ជាក់ដោយមន្ទីរពិសោធន៍បែងចែកតាមស្ថានភាពនៃការឆ្លង និងកាលបរិច្ឆេទនៃលទ្ធផលតេស្តវិជ្ជមាន ចាប់ផ្តើមពីថ្ងៃទី3 ខែមីនា ឆ្នាំ2020




**ក្រាហ្វិកទី2**: ពីរ៉ាមីតអាយុនៃករណីឈឺ និងករណីប្រហែលឆ្លងជំងឺកូវីដ-19




*សម្គាល់: របាយការណ៍នេះរៀបរៀងឡើងដោយនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាលសហការជាមួយមជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងអង្គការសុខភាពពិភពលោក*

**ក្រាហ្វិកទី3: ចំនួនករណីឈឺបញ្ជាក់ដោយមន្ទីរពិសោធន៍និងចំនួនអ្នកបានធ្វើតេស្តតាមខេត្ត-ក្រុង**




**ក្រាហ្វិកទី4: ចំនួនថ្ងៃគិតចាប់តាំងពីខេត្តនីមួយៗ បានបញ្ជូនវត្ថុវិភាគនៃករណីសង្ស័យមកធ្វើតេស្តនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា**




*សម្គាល់: របាយការណ៍នេះរៀបរៀងឡើងដោយនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាលសហការជាមួយមជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងអង្គការសុខភាពពិភពលោក*

ក្រាហ្វិកទី5: បង្ហាញពីចំនួនវត្ថុវិភាគត្រូវបានធ្វើតេស្តនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាដើម្បីតាមដានរកមេរោគសាកូវី-2 និងលទ្ធផលតេស្តប្រចាំថ្ងៃ




**ក្រាហ្វិកទី6:** ទំនោរនៃការហៅទូរស័ព្ទមកកាន់លេខ 115 សាកសួរស្តីពីជំងឺកូវីដ-19




*សម្គាល់: របាយការណ៍នេះរៀបរៀងឡើងដោយនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាលសហការជាមួយមជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងអង្គការសុខភាពពិភពលោក*

**ក្រាហ្វិកទី7**: ចំនួនវត្ថុវិភាគបានមកពីប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្តាសាយ (ILI) និងជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARI) នៅប្រទេសកម្ពុជាដែលត្រូវបានធ្វើតេស្តរកមេរោគជំងឺកូវីដ-19 ។ វត្ថុវិភាគទាំងអស់ត្រូវបានធ្វើ   តេស្តតែលទ្ធផលអវិជ្ជមានមេរោគ សាកូវី-2 ទាំងអស់។




*សម្គាល់: របាយការណ៍នេះរៀបរៀងឡើងដោយនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាលសហការជាមួយមជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងអង្គការសុខភាពពិភពលោក*